ព្រឹត្តិបត្រព័ត៌មាន

NEC BULLETIN

# គ.ជ.ប

## ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣

## ថ្ងៃអាទិត្យ ទី០៣ ខែមិថុនា ឆ្នាំ២០១២

លេខ ០៦ ចេញផ្សាយថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២




## មាតិកា

- វគ្គបណ្តុះបណ្តាលស្តីពីការបោះឆ្នោត រាប់សន្លឹកឆ្នោត........................ ២
- គណៈកម្មការរៀបចំការបោះឆ្នោតខេត្តប៉ៃលិន បានបើកវគ្គ............... ៦
- គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកែប បើកកិច្ចប្រជុំ................. ៧
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បង្កលក្ខណៈឲ្យ............... ៨
- គ.ជ.ប បង្ហាញទឹកខ្មៅលុបលាងមិនជ្រះ និងសន្លឹកឆ្នោតគំរូ...................... ១០
- សេចក្តីណែនាំរួមស្តីពីការធានានិរន្តរភាពការងាររបស់រដ្ឋបាល.......... ១១
- ទម្រង់ពាក្យសុំច្បាប់ឈប់សម្រាកពីការងារដើម្បីចូលរួមក្នុង................. ១៤
- ខិតប័ណ្ណស្តីពីការយល់ដឹងអំពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា.... ១៥



www.necelect.org.kh, www.voterlist.org.kh, Email: necinfo@forum.org.kh, Phone/Fax (023) 214 374

# វគ្គបណ្តុះបណ្តាលស្តីពីការបោះឆ្នោត រាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផល នៃការបោះឆ្នោតដល់មន្ត្រីបោះឆ្នោត និងតំណាងស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោត

ដើម្បីពង្រឹងសមត្ថភាពមន្ត្រីបោះឆ្នោតឲ្យកាន់តែមានប្រសិទ្ធិភាពថែមទៀតក្នុងការអនុវត្តការងារ ជាពិសេសដើម្បីឲ្យស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោត និងមន្ត្រីបោះឆ្នោតបានយល់ត្រឹមត្រូវពីការងារបោះឆ្នោត កាលពីថ្ងៃទី០៨-០៩ ខែឧសភា ឆ្នាំ២០១២កន្លងទៅនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានបើកវគ្គបណ្តុះបណ្តាលស្តីពីការបោះឆ្នោត រាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ ដល់ប្រធាន សមាជិកបណ្តុះបណ្តាល និងមន្ត្រីនៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត(គជ/ខប) តំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន ២៨១នាក់ ។



ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប មានប្រសាសន៍ក្នុងពិធីបិទវគ្គបណ្តុះបណ្តាល

ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប បានមានប្រសាសន៍ថា វគ្គនេះជាវគ្គចុងក្រោយសម្រាប់ការបណ្តុះបណ្តាលទាក់ទងនឹងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ។ ដូចនេះ មន្ត្រី គជ/ខប ទាំងអស់ត្រូវខិតខំយកចិត្តទុកដាក់ និងសហការគ្នាជាប្រចាំ ជាពិសេស ផ្តោតលើការបណ្តុះបណ្តាលនៅតាមវគ្គប្រមូលផ្តុំ ដែលសិក្ខាកាមជាមន្ត្រីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត(គឃ/សប) ។ ហើយសូមណែនាំ គឃ/សប ឲ្យបានច្បាស់លាស់អំពីច្បាប់ បទបញ្ញា និងនីតិវិធី ពីព្រោះមន្ត្រីទាំងនោះត្រូវបណ្តុះបណ្តាលបន្តដល់មន្ត្រីគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត(គកប/គករ) តទៅទៀត។

ឯកឧត្តមបានណែនាំថា មន្ត្រី គជ/ខប ទាំងអស់ត្រូវ ៖

- រៀបចំផែនការឱ្យបានច្បាស់លាស់មុននឹងបង្រៀនដល់ គឃ/សប ។
- ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាល ត្រូវធ្វើការស្ទាបស្ទង់ដើម្បីរកឱ្យឃើញថា តើ គឃ/សប ណាមួយនៅមានចំណុចខ្វះខាត ហើយត្រូវបញ្ជូនគ្រូទៅបង្រៀនដល់ គកប/គករ នៅឃុំ សង្កាត់នោះតែម្តង ពីព្រោះ



ថា ការបោះឆ្នោតតែមួយថ្ងៃទេ ល្អ ឬអាក្រក់នៅលើ គកប/គករ ហ្នឹងហើយ ។ ហើយបើ គកប/គករ ពុំ

មានសមត្ថភាពគ្រប់គ្រាន់ទេ នោះវាមានផលលំបាកហើយ ។

- យកចិត្តទុកដាក់លើសម្ភារបោះឆ្នោតដែល គ.ជ.ប បានបញ្ជូនទៅ ត្រូវការពារឱ្យបានគត់មុត និងត្រូវបញ្ជូនទៅ គឃ/សប និង គកប/គករ ឱ្យបានទាន់ពេលវេលា ។
- ត្រូវផ្សព្វផ្សាយ និងសហការជាមួយវិទ្យុនៅតាមបណ្តាខេត្ត ដើម្បីផ្សព្វផ្សាយនូវរាល់ឯកសារអប់រំសាធារណជនអំពីការបោះឆ្នោត ។
- រកវិធីសាស្ត្រចាក់ផ្សាយព័ត៌មានអំពីការបោះឆ្នោតជូនប្រជាពលរដ្ឋតាមមេក្រូនៅតាមភូមិ ។
- ត្រូវផ្សព្វផ្សាយព្រះរាជសារព្រះករុណា ដែលអំពាវនាវឱ្យប្រជាពលរដ្ឋទូទាំងប្រទេសចូលរួមបោះឆ្នោតឱ្យបានទូលំទូលាយ។

សូមរំលឹកថា ប្រធាន គឃ/ខប ទាំង២៤ ត្រូវបានអញ្ជើញចូលរួមក្នុងវគ្គបណ្តុះបណ្តាលខាងលើ ហើយព្រឹត្តិប័ត្រព័ត៌មាន គ.ជ.ប សូមធ្វើការចុះផ្សាយនូវរូបថតរបស់ប្រធាន គឃ/ខប ទាំងនេះ និងលេខទូរស័ព្ទទំនាក់ទំនងដូចខាងក្រោម ៖



លោក ហ៊ី គិមសេង
ប្រធាន គខប បន្ទាយមានជ័យ

លេខទូរស័ព្ទទំនាក់ទំនង :
០១២-៤៥៦-៧៥៤



លោក វ៉ន ពន
ប្រធាន គខប បាត់ដំបង

លេខទូរស័ព្ទទំនាក់ទំនង :
០១២-៨៨២-២៨៩



លោក មាង ម៉េងហ៊្សន
ប្រធាន គខប កំពង់ចាម

លេខទូរស័ព្ទទំនាក់ទំនង :
០១២-៨៨៤-៥៨៧



លោកស្រី នួន ចាន់នី
ប្រធាន គខប កំពង់ឆ្នាំង

លេខទូរស័ព្ទទំនាក់ទំនង :
០១១-៦៨៤-៦៧១ / ០៩៧-៧-៦៨៤-៦៧១



លោក ព្រុំ គីមថៃ
ប្រធាន គខប កំពង់ស្ពឺ

លេខទូរស័ព្ទទំនាក់ទំនង :
០១៦-៥៨៥-៤៩៧



លោក ប្រែង សាវុធ
ប្រធាន គខប កំពង់ធំ

លេខទូរស័ព្ទទំនាក់ទំនង :
០១២-៦១៨-១៦៥ / ០៨៨-៧-៧២២-៦៦៤



លោក តែ ជិនណារិទ្ធ
ប្រធាន គខប កំពត

លេខទូរស័ព្ទទំនាក់ទំនង :
០១៧-៨៨២-៨៨៤ / ០១៦-៣៣១-៣៣២



លោក គឹម ហុង
ប្រធាន គខប កណ្តាល

លេខទូរស័ព្ទទំនាក់ទំនង :
០១១-៣៩៣-៤១៦ / ០១២-៩៦៥-៧៨២



លោក សេង នេង
ប្រធាន គខប កោះកុង

លេខទូរស័ព្ទទំនាក់ទំនង :
០១១-៧៤០-៦០៦



លោក អ៊ុង ស៊ីយឿន
ប្រធាន គខប ក្រចេះ

លេខទូរស័ព្ទទំនាក់ទំនង :
០១២-៧៨៩-៤០៩



លោក ទី ឈឿន
ប្រធាន គខប មណ្ឌលគិរី

លេខទូរស័ព្ទទំនាក់ទំនង :
០១២-៩៦៩-២២០ / ០១១-៦៧២-៤០៨



លោក លន់ ឆេងកៃ
ប្រធាន គធប ភ្នំពេញ

លេខទូរស័ព្ទទំនាក់ទំនង :
០១២-៨៨០-០៨៤



លោក ឈឹម សំអឿន
ប្រធាន គខប ព្រះវិហារ

លេខទូរស័ព្ទទំនាក់ទំនង :
០១២-៩៧៤-៤៨១



លោក ហួត ផាន
ប្រធាន គខប ព្រៃវែង

លេខទូរស័ព្ទទំនាក់ទំនង :
០១២-៩៨៤-៨២៣



លោក ផាន់ វណ្ណសិទ្ធិ
ប្រធាន គខប ពោធិ៍សាត់

លេខទូរស័ព្ទទំនាក់ទំនង :
០១៦-៩៨៥-០១៦ / ០១២-៨២៧-៦៩៩



លោក ប៉ែន ឈុនឌី
ប្រធាន គខប រតនគិរី

លេខទូរស័ព្ទទំនាក់ទំនង :
០១២-៧៩១-៦១៦



លោក នឹម វ៉ាន់សំ
ប្រធាន គខប សៀមរាប

លេខទូរស័ព្ទទំនាក់ទំនង :
០១២-៨២០-១៨៥ / ០៩៧-៩-៤៩៩-៩៦៣



លោក ហួត ផុន
ប្រធាន គខប ព្រះសីហនុ

លេខទូរស័ព្ទទំនាក់ទំនង :
០១៦-៨២៤-០២៤



លោក ពុយ ចាន់ថាឡាក់
ប្រធាន គខប ស្ទឹងត្រែង

លេខទូរស័ព្ទទំនាក់ទំនង :
០១២-៩៤៤-៧៤១



លោក សួរ ទិត្យ
ប្រធាន គខប ស្វាយរៀង

លេខទូរស័ព្ទទំនាក់ទំនង :
០១៥-៥៦៨-៨៨៨



លោក នួន សាវ៉ែន
ប្រធាន គខប តាកែវ

លេខទូរស័ព្ទទំនាក់ទំនង :
០១៦-៧៣២-០១៧



លោក ម៉ុក សែន
ប្រធាន គខប កែប

លេខទូរស័ព្ទទំនាក់ទំនង :
០១២-៩៥៧-២៤២



លោកស្រី ប៊ុន សូតី
ប្រធាន គខប ប៉ៃលិន

លេខទូរស័ព្ទទំនាក់ទំនង :
០១១-៥៤០-០០២



លោក ជិញ សិត្ថ
ប្រធាន គខប ឧត្តរមានជ័យ

លេខទូរស័ព្ទទំនាក់ទំនង :
០១១-៧៣៧-៨៨២ / ០១២-៣៦៥-៦៨០

# គណៈកម្មការរៀបចំការបោះឆ្នោតខេត្តប៉ៃលិន បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការបោះឆ្នោត រាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត

ដើម្បីជានាឲ្យដំណើរការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតមួយ ប្រព្រឹត្តទៅដោយរលូន ប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព គឺទាមទារឲ្យមន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់មានការយល់ដឹងច្បាស់ ត្រឹមត្រូវ អំពីច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ។

ឆ្លើយតបទៅនឹងបញ្ហានេះ និងគោរពតាមប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម អ៊ឹម សួស្ដី ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត( គ.ជ.ប) នៅក្នុងពិធីបិទវគ្គបណ្តុះបណ្តាលស្តីពីការបោះឆ្នោត និងរាប់សន្លឹកឆ្នោត កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១២ នាថ្ងៃទី១៣-១៤ ខែឧសភា ឆ្នាំ២០១២ គណៈកម្មការរៀបចំការបោះឆ្នោតខេត្តប៉ៃលិន ( គខប) បានបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រី គខប តំណាងគណបក្សនយោបាយ និងតំណាងអង្គការមិនមែនរដ្ឋាភិបាល ស្តីពីការបោះឆ្នោត រាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ។ វគ្គបណ្តុះបណ្តាលនេះមានសិក្ខាកាមចូលរួមចំនួន ៣៨នាក់ ក្នុងនោះស្ត្រី ០៧នាក់ ។

តាមរបាយការណ៍ដែលផ្តល់ដោយ គខប ប៉ៃលិន បានឲ្យដឹងថា ប្រធានបទក្នុងវគ្គបណ្តុះបណ្តាលនេះរួមមាន ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត កិច្ចដំណើរការរួមរបស់គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត( គកប/គករ) កិច្ចដំណើរការរួមរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត( គឃ/សប) កិច្ចដំណើរការរួមរបស់ គខប ការវេចខ្ចប់ និងការបញ្ជូនសម្ភារ ។

បន្ទាប់ពីការបញ្ចាំងវីស៊ីឌី ការបង្ហាញ និងបកស្រាយទាក់ទងនឹងប្រធានបទរួចមក គ្រូឧទ្ទេសនាមបានធ្វើការចោទជាសំណួរឲ្យសិក្ខាកាមឆ្លើយ បកស្រាយពន្យល់បន្ថែមយ៉ាងផុលផុស ណែនាំឲ្យធ្វើលំហាត់ជាក់ស្តែង និងធ្វើតេស្តក្រោយពេលបញ្ចប់វគ្គ ។

របាយការណ៍ដដែលបានបង្ហាញថា លទ្ធផលនៃការធ្វើតេស្តក្រោយពីបញ្ចប់វគ្គបណ្តុះបណ្តាលគឺ សិក្ខាកាមមានការយល់ដឹងល្អណាស់មានចំនួន ១១% យល់ដឹងល្អមានចំនួន ៧៩% មធ្យម ២% និងខ្សោយ ៨%។

ជាមួយគ្នានេះ លោកស្រី ប៊ុន សូភី ប្រធាន គខប ប៉ៃលិន បានមានប្រសាសន៍ឲ្យដឹងតាមទូរស័ព្ទកាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២ថា បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាលខាងលើ គខប បានធ្វើការបណ្តុះបណ្តាលបន្តដល់ គឃ/សប ចប់រួចរាល់ហើយកាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ ៕


## ក្រុមរៀបចំព្រឹត្តិបត្រព័ត៌មាន គ.ជ.ប

**អ្នកគ្រប់គ្រង**

លោក មៃ សារី

**ក្រុមនិពន្ធ**

លោក មិន ពុធជេដ្ឋាវណ្ណ លោក សុខ លាត

លោក ទិន ករុណា

**កំណែអក្ខរាវិរុទ្ធ**

អ្នកស្រី ទិន សាវត្ថី

**អ្នកថតរូប**

លោក សាក់ បូរិន លោក គីម យុង

លោក រិន វុទ្ធី

**ក្រាហ្វិកកុំព្យូទ័រ**

លោក ប៉េង រតនៈ លោក ចាន់ វិបុល

# គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកែប បើកកិច្ចប្រជុំផ្សព្វផ្សាយ
## អំពីនីតិវិធីនៃការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣




កិច្ចប្រជុំរបស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកែប កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២

ស្របពេលដែលការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ចូលមកដល់ និងដើម្បីឲ្យការឃោសនាបោះឆ្នោតនេះបានប្រព្រឹត្តទៅដោយរលូន ជោគជ័យ និងប្រកបដោយសុខសន្តិភាព កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកែប( គខប) បានបើកកិច្ចប្រជុំមួយដើម្បីផ្សព្វផ្សាយអំពីនីតិវិធី និងការប្រព្រឹត្តទៅនៃការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ។ សមាសភាពចូលរួមមានមន្ត្រី គខប កែប មន្ត្រីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ( គឃ/សប) តំណាងគណបក្សប្រជាជនកម្ពុជា គណបក្សសមរង្ស៊ី និងគណបក្សហ៊្វុនស៊ិនប៉ិច ស្នងការនគរបាលខេត្ត មេបញ្ជាការកងរាជអាវុធហត្ថខេត្ត លោក លោកស្រីតំណាងគណៈបញ្ជាការឯកភាព ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលសរុបប្រមាណ ៤៣នាក់ ។

លោក ម៉ុក សែន ប្រធាន គខប កែប បានមានប្រសាសន៍ណែនាំនៅក្នុងកិច្ចប្រជុំនោះថា ៖

- គណបក្សនយោបាយទាំងអស់ត្រូវប្រកាន់ភ្ជាប់នូវក្រមសីលធម៌របស់ខ្លួន និងមានការយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក ។
- ហាមធ្វើសកម្មភាពឃោសនាដោយយកព្រះឆាយាល័ក្ខណ៍ ព្រះរាជឱង្ការ ព្រះរាជសារ ស្នាព្រះហស្ត និងព្រះនាមព្រះមហាក្សត្រ ព្រះមហាវីរៈក្សត្រ ព្រះមហាក្សត្រីព្រះវររាជមាតា រូបសញ្ញា គ.ជ.ប ទៅប្រើប្រាស់ដើម្បីរកសម្លេងឆ្នោត ។
- គណបក្សនយោបាយ បេក្ខជន សកម្មជន និងអ្នកគាំទ្រ មិនត្រូវប្រើប្រាស់សម្ភារ ប្រាក់កាស ទិញទឹកចិត្តអ្នកបោះឆ្នោតឡើយ ។
- ហាមប្រើប្រាស់មធ្យោបាយដឹកជញ្ជូនរបស់រដ្ឋដូចជា ៖ រថយន្ត ទោចក្រយានយន្ត ឬជលយានគ្រប់ប្រភេទ ដែលប្រើប្រាស់ស្លាកសញ្ញារាជការ រដ្ឋ នគរបាល ខេមរភូមិន្ទ និងរាជរដ្ឋាភិបាល លើកលែងតែរថយន្តព្រឹទ្ធសភា និងរដ្ឋសភា ។
- ហាមប្រើប្រាស់ពេលវេលាការងាររបស់រដ្ឋទៅចូល

តទៅទំព័រទី ៩

# ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បង្កលក្ខណៈឲ្យនិយោជិត កម្មករ កម្មការិនី បានឈប់សម្រាកដើម្បីចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣

ជារៀងរាល់ឆ្នាំដែលមានការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតសកល ក៏ដូចជាឆ្នាំដែលមានការបោះឆ្នោតសកល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតែងតែបានបង្កលក្ខណៈ ដល់និយោជិត កម្មករ កម្មការិនី ដែលបម្រើការងារនៅតាមរោងចក្រ សហគ្រាស និងគ្រឹះស្ថានទាំងអស់ បានឈប់សម្រាកដើម្បីទៅចូលរួមពិនិត្យបញ្ជីឈ្មោះ ចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត ។

នៅឆ្នាំ២០១២នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញសេចក្តីជូនដំណឹងមួយ លេខ ១៥៤ ក.ប/ស.ជ.ណ ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១២ ដែលបានអនុញ្ញាតឲ្យនិយោជិត កម្មករ កម្មការិនី ដែលបម្រើការងារនៅតាមរោងចក្រ សហគ្រាស និងគ្រឹះស្ថានទាំងអស់បានឈប់សម្រាកពី ១ថ្ងៃ ទៅ ៣ថ្ងៃ ដើម្បីចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ដែលប្រព្រឹត្តទៅនៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២ ។

លោក សន វិបុល បុគ្គលិករដ្ឋបាលនៃរោងចក្រ MENG IENG Garment Factory Ltd. ដែលមានអាសយដ្ឋាននៅសង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ បានឲ្យដឹងតាមទូរស័ព្ទកាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១២ ថា ខាងរដ្ឋបាលរោងចក្របានទទួលសេចក្តីជូនដំណឹងខាងលើរួចហើយ ។ នៅថ្ងៃបន្ទាប់ លោកនឹងជូនដំណឹងដល់និយោជិត កម្មករ កម្មការិនី ដែលកំពុងបម្រើការងារនៅរោងចក្រនេះបានជ្រាប ។

អ្នកស្រី ឈុន អ៊ី បុគ្គលិកផ្នែករដ្ឋបាលបម្រើការងារនៅរោងចក្រ M&V3 ដែលមានទីតាំងនៅសង្កាត់ចាក់អង្រែក្រោមបានថ្លែងថា អ្នកស្រីបានទទួលសេចក្តីជូនដំណឹងនេះដែរពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ប៉ុន្តែលោកស្រីពុំទាន់បានជូនដំណឹងនេះទៅនិយោជិត កម្មករ កម្មការិនីនៅឡើយទេ ហើយតាមគម្រោងគឺគ្រោងនឹងប្រកាសជូនដំណឹងនៅចុងខែឧសភានេះ ។ លោកស្រីបានរំលឹកដែរថា កាលពីពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១ រោងចក្រ M&V3 ក៏បានចេញសេចក្តីជូនដំណឹងអនុញ្ញាតឲ្យនិយោជិត កម្មករ កម្មការិនីឈប់សម្រាក ដើម្បីទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតផងដែរ ។



កម្មករ កម្មការិនីបម្រើការងារនៅរោងចក្រ M&V3 នៅសង្កាត់ចាក់អង្រែក្រោម

សេចក្តីជូនដំណឹងនេះមានខ្លឹមសារថា នាយក ឬម្ចាស់រោងចក្រ សហគ្រាស និងគ្រឹះស្ថានទាំងអស់ត្រូវបង្កលក្ខណៈ និងអនុញ្ញាតឱ្យនិយោជិត កម្មករ កម្មការិនីបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ទៅតាមលក្ខណៈជាក់ស្តែង និងអាសយដ្ឋានពិតប្រាកដ ដែលពួកគេត្រូវទៅបោះឆ្នោត ៖

១. និយោជិត កម្មករ កម្មការិនី ដែលកំពុងបម្រើការងារនៅក្នុងរាជធានីភ្នំពេញ និងក្នុងទីរួមខេត្តទាំង ២៤ ហើយត្រូវទៅបោះឆ្នោតនៅក្នុងរាជធានីភ្នំពេញផ្ទាល់ និងនៅក្នុងទីរួមខេត្តទាំងនោះផ្ទាល់ នឹងត្រូវអនុញ្ញាត

ឱ្យឈប់សម្រាករយៈពេល ១ថ្ងៃ គឺនៅ**ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២** ។

២. និយោជិត កម្មករ កម្មការិនី ដែលកំពុងបម្រើការងារនៅក្នុងរាជធានី ខេត្តទាំង ២៤ ហើយត្រូវទៅបោះឆ្នោតក្នុងរាជធានី ខេត្តនោះផ្ទាល់ នឹងត្រូវអនុញ្ញាតឱ្យឈប់សម្រាករយៈពេល ២ថ្ងៃ គឺនៅ**ថ្ងៃ ទី០៣-០៤ ខែមិថុនា ឆ្នាំ២០១២** ។

៣. និយោជិត កម្មករកម្មការិនីដែលកំពុងបម្រើការងារនៅក្នុងរាជធានីភ្នំពេញ ហើយត្រូវទៅបោះឆ្នោតនៅតាមបណ្តាខេត្តទាំង ២៤ និងកំពុងបម្រើការងារនៅតាមបណ្តាខេត្តទាំង ២៤ ហើយត្រូវទៅបោះឆ្នោតនៅរាជធានីភ្នំពេញ ឬកំពុងបម្រើការងារនៅតាមបណ្តាខេត្តណាមួយ ហើយត្រូវទៅបោះឆ្នោតនៅខេត្តណាមួយផ្សេងទៀត នឹងត្រូវអនុញ្ញាតឱ្យឈប់សម្រាករយៈពេល ៣ថ្ងៃ គឺនៅ**ថ្ងៃទី០២-០៤ ខែមិថុនា ឆ្នាំ២០១២** ។

សេចក្តីជូនដំណឹងនេះក៏បានបញ្ជាក់ផងដែរថា រាល់ការអនុវត្តច្បាប់ជូននិយោជិត កម្មករ កម្មការិនី ក្នុងពេលទៅបោះឆ្នោត និយោជកត្រូវរក្សាទុកប្រាក់ឈ្នួល និងប្រាក់រង្វាន់ដែលធ្វើការទៀងទាត់ជូននិយោជិត កម្មករ កម្មការិនីនៅដដែល និងពុំតម្រូវឲ្យបង្ហាញឯកសារផ្សេងៗដល់និយោជករបស់ខ្លួន នៅពេលដែលត្រឡប់មកវិញឡើយ ។ ចំពោះនិយោជិត កម្មករ កម្មការិនី ដែលអវត្តមានហួសច្បាប់អនុញ្ញាត ត្រូវទទួលខុសត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ សហគ្រាស និងគ្រឹះស្ថាន ។ ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ត្រូវខិតខំបើកប្រាក់ឈ្នួលឱ្យនិយោជិត កម្មករ កម្មការិនី ឱ្យបានមុនថ្ងៃទៅបោះឆ្នោត ។ បើពុំមានលទ្ធភាពបើកប្រាក់ឈ្នួលទេ សូមអនុញ្ញាតឱ្យនិយោជិត កម្មករ កម្មការិនី ខ្ចីប្រាក់ឈ្នួលមួយភាគ(បុរេប្រទាន) ជាមុនសិន ៕

តមកពីទំព័រទី ៧ គណៈកម្មការរៀបចំការបោះ...



លោក ម៉ុក សែន ប្រធាន គខប កែប

រួមឃោសនា ឬបញ្ចុះបញ្ចូល បម្រើឲ្យគណបក្សនយោបាយណាមួយឡើយ លើកលែងតែថ្ងៃឈប់សម្រាក ឬចប់ម៉ោងការងារ ឬក្រៅម៉ោងការងារ ឬស្ថិតនៅក្នុងច្បាប់ឈប់សម្រាក ។

- រាល់សកម្មភាពឃោសនាបោះឆ្នោតត្រូវបញ្ឈប់ក្នុងរយៈពេល ២៤ម៉ោង មុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត (ហាមធ្វើការឃោសនានាថ្ងៃទី០២ និងទី០៣ ខែមិថុនា ឆ្នាំ២០១២) ។

ជាមួយគ្នានេះដែរ គណៈបញ្ជាការឯកភាពខេត្ត ក្រុង ស្រុក បានធ្វើការសំណូមពរដល់គណបក្សនយោបាយទាំងអស់ ក្នុងអំឡុងពេលឃោសនា ត្រូវគោរពតាមកម្មវិធី ពេលវេលា ទីកន្លែង ដែលខ្លួនបានដាក់ជូន គឃ/សប សូមឲ្យមានកិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការការពារសន្តិសុខសុវត្ថិភាពជូនគណបក្សនយោបាយទាំងអស់ ដើម្បីឲ្យដំណើរការឃោសនាបោះឆ្នោតនេះទទួលបានជោគជ័យ និងជួយអន្តរាគមន៍ឲ្យបានទាន់ពេលវេលា ក្នុងករណីមានភាពមិនប្រក្រតីកើតឡើងដោយថាហេតុ ៕

# គ.ជ.ប បង្ហាញទឹកខ្មៅលុបលាងមិនជ្រះ និងសន្លឹកឆ្នោតគំរូ

ទឹកខ្មៅលុបលាងមិនជ្រះចំនួន ៣៦.៩៦០ដប នឹងត្រូវប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត( គ.ជ.ប) បានបង្ហាញជាសាធារណៈនូវទឹកខ្មៅលុបលាងមិនជ្រះនេះ នៅក្នុងកិច្ចប្រជុំមួយនាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២ ដល់គណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មានសរុបប្រមាណ ៥០នាក់ ។





លោកជំទាវបណ្ឌិត ស៊ីន ជុំបូ អនុប្រធាន គ.ជ.ប មានប្រសាសន៍នៅក្នុងកិច្ចប្រជុំកាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២

លោកជំទាវបណ្ឌិត ស៊ីន ជុំបូ អនុប្រធាន គ.ជ.ប បានមានប្រសាសន៍ថា ទឹកខ្មៅទាំងនេះ ១ដប មានចំណុះ ៧០សង់ទីលីត្រ( CC) ហើយត្រូវបានបញ្ជាទិញពីក្រុមហ៊ុនមួយឈ្មោះថា Mysore Paints & Varnish Ltd. នៃប្រទេសឥណ្ឌា ។ លោកជំទាវបានបញ្ជាក់ថា សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មានការិយាល័យបោះឆ្នោតចំនួន ១៨.១០៧ការិយាល័យ ហើយក្នុងមួយការិយាល័យត្រូវប្រើប្រាស់ទឹកខ្មៅលុបលាងមិនជ្រះចំនួន ២ដប ។ ទឹកខ្មៅទាំងនេះ មួយចំនួនត្រូវទុកបម្រុងនៅ គ.ជ.ប និងនៅគណៈកម្មការរាជធានី ខេត្តរៀបចំបោះឆ្នោត( គជ/ខប) ។

កិច្ចប្រជុំនោះក៏បានបង្ហាញសន្លឹកឆ្នោតគំរូផងដែរ ដោយសន្លឹកឆ្នោតគំរូនេះមានចំនួន ១.៦៣៣ប្រភេទ តម្រូវតាមចំនួនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់ ហើយត្រូវបានបោះពុម្ពជា ២ ទម្រង់ គឺទម្រង់ A4 សម្រាប់ឃុំ សង្កាត់ដែលមានគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតចាប់ពី ១គណបក្ស ទៅ ៦គណបក្ស និងទម្រង់ F4 សម្រាប់ឃុំ សង្កាត់ដែលមានគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតចាប់ពី ៧គណបក្ស។ គ.ជ.ប បានបោះពុម្ពសន្លឹកឆ្នោតគំរូចំនួន ៨១.៦៥០ សន្លឹក ។ លោកជំទាវអនុប្រធាន គ.ជ.ប បានបញ្ជាក់ទៀតថា សន្លឹកឆ្នោតគំរូដែល គ.ជ.ប បោះពុម្ពនេះ សម្រាប់ធ្វើជាឯកសារបណ្តុះបណ្តាលដល់ គជ/ខប គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត( គឃ/សប) គណៈកម្មការការិយាល័យបោះឆ្នោត( គកប) និងអប់រំសាធារណជនតែប៉ុណ្ណោះ ។ សន្លឹកឆ្នោតសម្រាប់បម្រើការបោះឆ្នោតទាំងអស់មាន ១០.៦១៩.៨៥០ សន្លឹក ។

លោកជំទាវបានបញ្ជាក់នៅក្នុងកិច្ចប្រជុំនោះទៀតថា នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១២ ជាថ្ងៃចាប់ផ្តើមនៃការឃោសនាបោះឆ្នោត គ.ជ.ប គជ/ខប និង គឃ/សប បានត្រៀមលក្ខណៈរួចរាល់ ដើម្បីជួយសម្រួលដល់សកម្មភាពឃោសនារបស់គណបក្សនយោបាយ ហើយលោកជំទាវក៏បានអំពាវនាវដល់អាជ្ញាធរមានសមត្ថកិច្ចសូមឱ្យជួយសហការតាមនីតិវិធី ធ្វើយ៉ាងណាដើម្បីឱ្យការឃោសនាបោះឆ្នោតប្រព្រឹត្តទៅតាមច្បាប់ បទបញ្ជា និងនីតិវិធី និងគ្មានអំពើហិង្សា ។/

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ និង
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ...០១៥...[illegible]

# សេចក្ដីណែនាំរួម

## ស្ដីពី

## ការធានានិរន្តរភាពការងាររបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងរយៈពេលយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

- យោងព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- យោងព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- យោងព្រះរាជក្រមលេខ នស/រកម/០៧១១/០១២ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- យោងអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្ដីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- យោងតាមបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវតាមវិធានដែលបានចែងក្នុងច្បាប់ បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងធានានិរន្តរភាពការងាររបស់រដ្ឋបាលឃុំ សង្កាត់ប្រកបដោយប្រក្រតីភាពក្នុងរយៈពេលដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសូមធ្វើការណែនាំដូចខាងក្រោម ៖

**១-ចំពោះមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់**

ចាប់ពីពេលបើកយុទ្ធនាការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោត មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវខិតខំពង្រឹងសាមគ្គីភាព និងសហប្រតិបត្តិការជាមួយគ្នាដើម្បីបំពេញការងារឱ្យបានត្រឹមត្រូវតាមគោលការណ៍ច្បាប់ និងត្រូវប្រកាន់ជំហរអព្យាក្រឹតនិងមិនលំអៀង។

ចំពោះមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មានសិទ្ធិធ្វើសកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោត

១

ដោយស្មើភាពដូចបេក្ខជនដទៃទៀតដែរ តែមិនត្រូវប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឥទ្ធិពលនៃរដ្ឋបាលឃុំ សង្កាត់ និងមិនត្រូវប្រើប្រាស់មធ្យោបាយ សម្ភារៈ ថវិការបស់រដ្ឋបាលឃុំ សង្កាត់ទៅបម្រើសកម្មភាពគណបក្សនយោបាយណាមួយ ឬបម្រើសកម្មភាពយុទ្ធនាការឃោសនារបស់គណបក្សនយោបាយណាមួយឡើយ។

ក្នុងអំឡុងពេលនៃយុទ្ធនាការឃោសនាបោះឆ្នោត ដើម្បីធានានិរន្តរភាពការងារក្នុងឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ និងជំទប់ ចៅសង្កាត់រង ត្រូវពិភាក្សាគ្នារៀបចំបែងចែកវេនប្រចាំការតាមថ្ងៃនីមួយៗនៅសាលាឃុំ សង្កាត់ ដោយស្មើភាពក្នុងចំណោមមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង រួមទាំងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដទៃទៀត ដើម្បីធានាឱ្យមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់យ៉ាងតិចចំនួន ០១រូប សម្រាប់ប្រចាំការតាមថ្ងៃនីមួយៗ។ លិខិតចាត់តាំងវេនប្រចាំការនេះត្រូវថតចម្លង ០១ច្បាប់ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ០១ច្បាប់ជូនគណៈអភិបាលក្រុង ស្រុក ខណ្ឌសាមី និង០១ច្បាប់ទៀតបិទផ្សាយនៅតាមសាលាឃុំ សង្កាត់។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវបានចាត់តាំងឱ្យប្រចាំការនេះ ត្រូវទទួលសម្របសម្រួលកិច្ចការរដ្ឋបាលប្រចាំថ្ងៃ ការអភិវឌ្ឍ សំណើ ឬសំណូមពរផ្សេងៗរបស់ប្រជាពលរដ្ឋរបស់ខ្លួនស្របតាមគោលការណ៍ច្បាប់ និងលិខិតបទដ្ឋាននានាសម្រាប់គ្រប់គ្រងឃុំ សង្កាត់។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវបានចាត់តាំងឱ្យប្រចាំការ មិនត្រូវចូលរួមក្នុងយុទ្ធនាការឃោសនារបស់គណបក្សនយោបាយណាមួយនៅក្នុងថ្ងៃដែលសាមីខ្លួនត្រូវប្រចាំការនោះឡើយ។ ក្នុងពេលប្រចាំការ ករណីមានកិច្ចការដែលត្រូវសម្រេច និងចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលទទួលវេនប្រចាំការនោះត្រូវទាក់ទងជាបន្ទាន់ជាមួយមេឃុំ ចៅសង្កាត់ដើម្បីដោះស្រាយការងារទាំងនោះ ឱ្យបានសមស្របទៅតាមគោលការណ៍ច្បាប់។

## ២-ចំពោះស្មៀនឃុំ សង្កាត់

ស្មៀនឃុំ សង្កាត់ដែលជាមន្ត្រីរាជការស៊ីវិលត្រូវមានវត្តមានជាប្រចាំនៅសាលាឃុំ សង្កាត់ នៅរៀងរាល់ថ្ងៃការងារ។ ស្មៀនឃុំ សង្កាត់ត្រូវប្រកាន់អាកប្បកិរិយាការងារស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតដែលទាក់ទងនឹងគណបក្សនយោបាយ និងការបោះឆ្នោត ដូចមន្ត្រីរាជការស៊ីវិលដទៃទៀតដែរ។

## ៣-ចំពោះមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ

មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមសៀវភៅណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតស្តីពីភារកិច្ច និងកាតព្វកិច្ចរបស់មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិក្នុងដំណើរការបោះឆ្នោត។

មេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ ដែលមានបំណងចូលរួមក្នុងយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬជាបេក្ខជន ត្រូវដាក់ពាក្យសុំច្បាប់ឈប់សម្រាកពីការងារទៅមេឃុំ ចៅសង្កាត់សាមីដើម្បីចូលរួមក្នុងសកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោត របស់គណបក្សនយោបាយណាមួយ (តាមគំរូពាក្យសុំច្បាប់ភ្ជាប់មកជាមួយ)។ ប៉ុន្តែក្នុងភូមិនីមួយៗ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិមិនត្រូវដាក់ពាក្យសុំឈប់សម្រាកក្នុងពេលតែមួយជាមួយគ្នា ដោយមិនមានអ្នកប្រចាំការដោះស្រាយការងារសាធារណៈក្នុងភូមិនោះឡើយ។ ពាក្យសុំច្បាប់ឈប់សម្រាកនេះត្រូវថតចម្លង ០១ច្បាប់ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត។

ក្នុងអំឡុងពេលនៃការឈប់សម្រាកពីការងារ ដើម្បីចូលរួមក្នុងសកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោត មេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ មិនមែនជាមន្ត្រីដឹកនាំភូមិឡើយ។

អ្នកដឹកនាំភូមិដទៃទៀតដែលមិនបានសុំច្បាប់ឈប់សម្រាកពីការងារ គឺជាអ្នកដឹកនាំភូមិតាមឋានានុក្រមដែលត្រូវបម្រើកិច្ចការសាធារណៈក្នុងភូមិប្រកបដោយតម្លាភាព និងត្រូវប្រកាន់ជំហរអព្យាក្រឹត ឥតលំអៀងក្នុងការបោះឆ្នោត ហើយមន្ត្រីភូមិទាំងនោះមិនត្រូវចូលរួមក្នុងសកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោត របស់គណបក្សនយោបាយណាមួយឡើយ ប្រសិនបើសាមីខ្លួនមិនមានច្បាប់ឈប់សម្រាកពីការងារ។

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន និងអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ក្រុមប្រឹក្សារាជធានី ខេត្ត គណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ អគ្គលេខាធិការ គ.ជ.ប គធ/ខប និង គឃ/សប ត្រូវចាត់ចែងផ្សព្វផ្សាយទូលំទូលាយ និងណែនាំអនុវត្តសេចក្តីណែនាំរួមនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី...១០... ខែ...ឧសភា... ឆ្នាំ២០១២

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

អ៊ឹម សូស៊ី

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ កាលប្បវត្តិ

៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឃុំ សង្កាត់...........................

**ពាក្យសុំច្បាប់ឈប់សម្រាកពីការងារ**
**ដើម្បីចូលរួមក្នុងយុទ្ធនាការឃោសនាបោះឆ្នោត**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..............................................ឋានៈជា...............................................

**សូមគោរពជូន**
**លោក/លោកស្រី មេឃុំ ចៅសង្កាត់.........................................**

**កម្មវត្ថុ** ៖ សំណើសុំច្បាប់សម្រាកពីការងារដឹកនាំភូមិរយៈពេល...........ថ្ងៃ ចាប់ពីថ្ងៃទី..........ខែ.............. ដល់ថ្ងៃទី..........ខែ...............ឆ្នាំ.............។

**យោង** ៖ សេចក្តីណែនាំរួមរបស់ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការធានានិរន្តរភាពការងាររបស់រដ្ឋបាលឃុំ សង្កាត់ក្នុងរយៈពេលយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ដោយខ្ញុំបាទ/នាងខ្ញុំត្រូវចូលរួមក្នុងសកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោតរយៈពេល............ថ្ងៃ ចាប់ពីថ្ងៃទី...........ខែ...............ដល់ថ្ងៃទី........... ខែ.............. ឆ្នាំ..............។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីមេឃុំ ចៅសង្កាត់មេត្តាអនុញ្ញាតច្បាប់ឱ្យខ្ញុំបាទ/នាងខ្ញុំបានឈប់សម្រាកពីការងារដឹកនាំភូមិក្នុងរយៈពេលស្នើសុំខាងលើ តាមការគួរ។

*ថ្ងៃទី...........ខែ.................ឆ្នាំ.............*

**ហត្ថលេខា**

បានឃើញ និងឯកភាព
**មេឃុំ ចៅសង្កាត់**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គ.ជ.ប

# ខិត្តប័ណ្ណស្តីពី

## ការយល់ដឹងអំពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៣

## ថ្ងៃអាទិត្យ ទី០៣ ខែមិថុនា ឆ្នាំ២០១២

ថ្ងៃ**អាទិត្យ** ទី០៣ ខែមិថុនា ឆ្នាំ**២០១២** ជាឱកាសមួយដ៏វិសេសវិសាលបំផុតក្នុងរយៈពេល ៥ ឆ្នាំម្តង សម្រាប់ប្រជាពលរដ្ឋខ្មែរដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ដើម្បីជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។

- យើងជាប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលរស់នៅក្នុងឃុំ សង្កាត់ មានភារកិច្ចចូលរួមបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួនតាមច្បាប់កំណត់ ដើម្បីរួមចំណែកអភិវឌ្ឍឃុំ សង្កាត់ ។
- ប្រជាពលរដ្ឋដែលបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ ប៉ុន្តែពុំបានទៅបោះឆ្នោត គឺធ្វើឱ្យបាត់សិទ្ធិរបស់ខ្លួនឯងក្នុងការចូលរួមកសាងសង្គមជាតិ ។
- ភូមិ ឃុំ សង្កាត់ អភិវឌ្ឍទៅបាន និងមានសុវត្ថិភាព គឺអាស្រ័យលើក្រុមប្រឹក្សាឃុំ សង្កាត់ឈ្លាសវៃ និងមានសមត្ថភាព ។
- ដើម្បីមានក្រុមប្រឹក្សាឃុំ សង្កាត់ឈ្លាសវៃ និងមានសមត្ថភាព យើងត្រូវចូលរួមបោះឆ្នោតទាំងអស់គ្នាតាមលទ្ធិប្រជាធិបតេយ្យ ដោយសេរី និងដោយសម្ងាត់ ។
- យើងត្រូវដឹងឱ្យបានច្បាស់អំពីលេខរៀងឈ្មោះរបស់យើង លេខកូដ និងទីតាំងការិយាល័យបោះឆ្នោតដែលមានបញ្ជាក់ក្នុងបញ្ជីបោះឆ្នោតដែលបានបិទផ្សាយ ឬក្នុងប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ។
- យើងត្រូវត្រៀមពេលវេលា និងឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ប្រើនៅថ្ងៃបោះឆ្នោត ។
- គ្មានការគំរាមកំហែង ឬការបង្ខិតបង្ខំណាមួយមកលើរូបយើងឱ្យបោះឆ្នោតជូនគណបក្សនយោបាយណាមួយបានឡើយ ។
- គ្មានអ្នកណាម្នាក់អាចដឹងថា យើងបោះឆ្នោតជូនគណបក្សនយោបាយណាមួយឡើយ ព្រោះយើងគូសសន្លឹកឆ្នោតក្នុងបន្ទប់សម្ងាត់តែម្នាក់ឯងគត់ ។
- អ្នកបោះឆ្នោតម្នាក់ៗមានសិទ្ធិបោះឆ្នោតតែមួយសន្លឹក និងតែមួយដងគត់ ដោយត្រូវទៅបោះឆ្នោតដោយខ្លួនឯងផ្ទាល់ ។

**ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៣**

**ប្រព្រឹត្តទៅនៅ ថ្ងៃអាទិត្យ ទី០៣ ខែមិថុនា ឆ្នាំ២០១២**

**ចាប់ពីម៉ោង ៧:០០ ព្រឹក ដល់ម៉ោង ៣:០០ រសៀល ។**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ**
**នរោត្តម  សីហមុនី**
**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

**ផ្ញើជូនជនរួមជាតិ  បងប្អូន  កូនក្មួយ  ជាទីគោរពស្នេហាដ៏ជ្រាលជ្រៅបំផុត**

ដោយថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ  សង្កាត់  កាន់តែខិតជិតមកដល់ហើយ  ខ្ញុំសូមធ្វើសេចក្តីអំពាវនាវជាឱឡារិក ជូនជនរួមជាតិ បងប្អូន កូនក្មួយ សុំកុំឱ្យមានការព្រួយបារម្ភចំពោះការគាបសង្កត់ ការគំរាមកំហែង ឬសំឡុតពីជនណាមួយ  បក្សណាមួយ  ឱ្យសោះ។

ការបោះឆ្នោត នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១២  គឺជាការបោះឆ្នោតសម្ងាត់  ហើយដែលនឹងប្រព្រឹត្តធ្វើទៅតាមលទ្ធិប្រជាធិបតេយ្យសេរី ។

ហេតុដូចនេះ ខ្ញុំសូមបងប្អូន កូនក្មួយ មេត្តាប្រើសិទ្ធិរបស់ខ្លួន គឺបោះឆ្នោតទៅតាមសតិសម្បជញ្ញៈរបស់ខ្លួនម្នាក់ៗ ដែលមានទំនុកចិត្តទៅលើបេក្ខជនណាមួយ បក្សណាមួយ  បានដោយសេរី ។

សូមបងប្អូន កូនក្មួយ ជនរួមជាតិទាំងអស់ ប្រកបនូវព្រះពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងមេត្តាទទួលនូវសេចក្តីគោរពស្នេហាដ៏ជ្រាលជ្រៅជាទីបំផុតអំពីខ្ញុំ ។

ន សីហមុនី

**នរោត្តម  សីហមុនី**

*រាជធានីភ្នំពេញ ថ្ងៃទី  ០៨  ខែ មីនា  ឆ្នាំ ២០១២*